# II - និតិវិធីការគណៈរដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ : ៣៧ អនក្រ.បក**

**អនុក្រឹត្យស្តីពីបែបបទសំរាប់អនុវត្តចំពោះការអនុញ្ញាតអោយ ជនបរទេសអន្តោប្រវេសន្ត ជាអ្នកវិនិយោគចេញ-ចូល និង ស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១០៩៤-៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកត-០១៩៦-០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៥ ន/ស ៩៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤ ស្តីពីអន្តោប្រវេសន៍

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តាមការយល់ព្រមនៃគណៈរដ្ឋមន្ត្រី

## សំរេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ :** អនុក្រឹត្យនេះកំណត់អំពីបែបបទ សំរាប់អនុវត្តចំពោះការអនុញ្ញាតអោយជនបរទេសអន្តោប្រវេសន្តជាអ្នកវិនយោគចេញ–ចូល និង ស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមាន ចែងក្នុងមាត្រា ២៨ ជំពូកទី ៤ នៃ ច្បាប់ស្តីពីប្រវេសន្ត ។

## ជំពូកទី ២

## បែបបទក្នុងការសុំចូលមកស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា

**មាត្រា ២ :** ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគដែលបានទទួលលិខិតអនុញ្ញាតអោយវិនិយោគពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ ពីស្ថាប័នមានសមត្ថកិច្ចកម្ពុជា មានបំណងចូលមកស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចដាក់ពាក្យសុំទិដ្ឋាការចូល ព្រះរាជាណាចក្រកម្ពុជា ដោយផ្ទាល់មកក្រសួងមហាផ្ទៃ ឬ តាមរយៈអាជ្ញាធរទូត ឬ កុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ឬ អាជ្ញាធរបរទេសណាមួយតំណាងអោយផលប្រយោជន៍ នៃព្រះរាជាណាចក្រកម្ពុជា នៅក្រៅប្រទេសដោយ :

១- ត្រូវបំពេញបែបបទទិដ្ឋាការ

២- ត្រូវបង្ហាញលិខិតឆ្លងដែនរបស់ខ្លួន ឬ ឯកសារធ្វើដំណើរណាមួយ ដែលមានតម្លៃ ស្មើគ្នា ដែលមាន សុពលភាពយ៉ាងតិច ៦ ខែ មុនថ្ងៃចូលព្រះរាជាណាចក្រកម្ពុជា ។

៣- ត្រូវផ្តល់រូបថត ៤ × ៦ ចំនួន៣ សន្លឹក ថតចំពីមុខគ្មានពាក់វ៉ែនតាខ្មៅ ដែលទើបនឹងថត មិនលើសពី ៦ ខែ ។

៤- ត្រូវផ្តល់វិញ្ញាបនប័ត្របញ្ជាក់សុខភាព ចំនួនមួយច្បាប់ ដែលចេញអោយដោយវេជ្ជបណ្ឌិត ទទួលស្គាល់ជាផ្លូវការបញ្ជាក់ពីស្ថានភាពសុខភាព ។ វិញ្ញាបនប័ត្រនេះ ត្រូវមានកាលបរិច្ឆេទមិនហួសពី ៣ ខែ

៥- ត្រូវផ្តល់លិខិតថ្កោលទោសដែលចេញអោយដោយអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេស ដើមរបស់ខ្លួន ឬ លិខិតបញ្ជាក់ណាមួយដែលមានតម្លៃដូចគ្នា ។

៦- ត្រូវបង់អាករទិដ្ឋាការចំនួនពីរសែនប្រាំម៉ឺនរៀល ( ២៥០.០០០៛០០) ។

មាត្រា ៣ : សមាជិកគ្រួសារផ្ទាល់ខ្លួនរបស់ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគ គឺ ប្តី ឬ ប្រពន្ធ កូននៅលីវស្ថិតនៅក្នុងបន្ទុក ឪពុក ម្តាយបង្កើត ឪពុក ម្តាយក្មេកស្ថិតនៅក្នុងបន្ទុក និង អ្នកស្ថិតក្នុងបន្ទុកគ្រប់គ្រង ត្រូវបំពេញបែបបទដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ។ កុមារមានអាយុ ១២ឆ្នាំចុះមិនបាច់បំពេញបែបបទទិដ្ឋាការដោយឡែកទេ តែត្រូវចុះឈ្មោះ និងបិទរូបថតរួមជាមួយឪពុក ម្តាយ ឬអាណាព្យាបាលប៉ុណ្ណោះ ប៉ុន្តែត្រូវបង់អាករ ទិដ្ឋាការចំនួន មួយសែនពីរម៉ឺនប្រាំពាន់រៀល ( ១២៥.០០០៛០០ ) ក្នុងម្នាក់ ។

មាត្រា ៤ : ការទទួលស្គាល់ជនបរទេសណាមួយថាជាជនបរទេសអន្តោប្រវេសន្ត ជាអ្នកវិនិយោគ ត្រូវ សំរេចដោយប្រកាសរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៥ : អាករទិដ្ឋាការគ្រប់ប្រភេទខាងលើនេះ ត្រូវបង់ចូលថវិកាជាតិ ។ បែបបទនៃការប្រមូលអាករទិដ្ឋាការនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ។

## ជំពូកទី៣
## ការស្នាក់នៅ

**មាត្រា ៦ :** ជនបរទេសដែលបានទទួលលក្ខណៈសម្បត្តិជាជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគព្រមទាំងគ្រួសារផ្ទាល់អាចស្នាក់នៅជាអចិន្ត្រៃយ៍ឬតាមរយៈពេលដែលបានកំណត់ក្នុងលិខិតអនុញ្ញាតអោយវិនិយោគ ក្នុងព្រះរាជាណាចក្រកម្ពុជាបន្ទាប់ពីបានទទួលប័ណ្ណស្នាក់នៅចេញអោយដោយក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤
## ការដកហូតលក្ខណសម្បត្តិជាជនបរទេសអន្តោប្រវេសន៍ ជាអ្នកវិនិយោគ

**មាត្រា ៧ :** អាចត្រូវដកហូតលក្ខណសម្បត្តិជាជនបរទេសអន្តោប្រវេស្តន៍ ជាអ្នកវិនិយោគដោយ ប្រកាសរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ចំពោះជនបរទេសអន្តោប្រវេស្តន៍ ជាអ្នកវិនិយោគណាដែលបានប្រព្រឹត្តល្មើស នឹងបទបញ្ញត្តិនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ហើយដែល ត្រូវតុលាការផ្តន្ទាទោស ចាប់ពីបទឧក្រិដ្ឋឡើងទៅ ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ៨ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ គ្រប់ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ១៤១ អនក្រ.តក**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តរតនគីរី